**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........................................................

ថ្ងៃអាទិត្យ ២កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្តូរប្រាក់បាតថៃ នៅគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ដើម្បីសម្រួលដល់ការប្តូរប្រាក់បាតថៃ សម្រាប់បងប្អូនប្រជាពលរដ្ឋដែលមកពីប្រទេសថៃ ធនាគារជាតិនៃកម្ពុជា បានផ្តល់ការណែនាំដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ ក្នុងការផ្តល់សេវាប្តូរប្រាក់បាតក្នុងអត្រាទីផ្សារ។ បច្ចុប្បន្ន សាខាធនាគារ អេស៊ីលីដា បានអនុវត្តតាមការជូនដំណឹងនេះ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ផ្សេងៗទៀតនឹងបន្តអនុវត្តការប្តូរប្រាក់នេះ ដើម្បីការពារផលប្រយោជន៍របស់បងប្អូនប្រជាពលរដ្ឋ។

ធនាគារជាតិនៃកម្ពុជា សូមអំពាវនាវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងអាជីវករប្តូរប្រាក់ទាំងអស់ចូលរួមសហការទទួលប្តូរប្រាក់បាតថៃទៅប្រាក់រៀលក្នុងអត្រាទីផ្សារ ដោយស្មារតីសាមគ្គីភាព និងជួយគ្នាទៅវិញទៅមកក្នុងកាលៈទេសៈនេះ។

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៨៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
**បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia ,
www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA